# អ្នកនាំសារ
## The Messenger

24

ខែ មិថុនា ឆ្នាំ ២០០៥- ព័ត៌មានពីព្រះសហគមន៍កាតូលិក



# គាំពារកុមារដើម្បីអនាគតកាន់តែប្រសើរ



អំពើហិង្សា! នៅផ្ទុះអារម្មណ៍ប្រជាជនខ្មែរ
ទំព័រ ២



ចូលរួមពិធីតែងតាំងឧបដ្ឋាកថ្មី
ទំព័រ ៧

ព្រះសហគមន៍ កំពង់ចាមលើក ស្ទួយសិទ្ធិកុមារ
ទំព័រ ៩

បើមើលពីសំបកក្រៅទៅ ប្រជាជនខ្មែរហាក់ដូចជារស់នៅក្នុងសេចក្ដីស្ងប់ស្ងាត់ និងពុំសូវចេះនិយាយស្ដីច្រើន។ តាមពិតរវាងការអប់រំក្នុងគ្រួសារតាមបែបបុរាណ ស្របពេលនឹងមានការវិវឌ្ឍន៍របស់សង្គម ប្រជាជនខ្មែរហាក់ដូចជាកំពុងស្ថិតក្នុងស្ថានភាពបាក់ស្បាត ទន្ទឹមនឹងការកំពុងឈានបោះជំហានយ៉ាងយឺតៗ ដើម្បីរំដោះខ្លួនឱ្យរួចចាកផុតចេញពីភាពក្រីក្រ។
ជាការពិតណាស់ ប្រជាជននេះកំពុងរស់នៅដោយត្រូវបានរុំព័ទ្ធជុំវិញទៅដោយរូបភាពហិង្សាគ្រប់បែបយ៉ាង។ "អ្នកនាំសារ" បានជួបវាគ្មិនសំខាន់ៗមួយចំនួន ដែលបានចូលរួមរិះគិត និងរែកញែករកហេតុផលផ្សេងៗ ចំពោះបញ្ហានេះ។

# អំពើហិង្សា! នៅជុំវិញអារម្មណ៍ប្រជាជនខ្មែរ




Image: Neak Chea

ច្បាប់រដ្ឋធម្មនុញ្ញមាត្រា៣៨ ចែងថា ច្បាប់ការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។



Photo: DR

នៅលេខក្រោយៗ នឹងមានអត្ថបទអង្កេតមួយទៀត គឺ កង្វះការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ។ បើសិនប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជជែកពិភាក្សាលើអត្ថបទ សូមផ្ញើសំបុត្រមកកាន់ "អ្នកនាំសារ" តាមរយៈលោកឪពុកនៅជិតបំផុត។

អស់រយៈពេលជាង៣០ឆ្នាំមកហើយ ដែលប្រជាជនខ្មែរបានស្គាល់តែទុក្ខវេទនាចំពោះសង្គ្រាម។ ការព្រាត់ប្រាស់គ្រួសារ និងការកាប់សម្លាប់គ្នាអស់រយៈពេលជាយូរឆ្នាំកន្លងមកនេះ បានជំរុញឱ្យប្រជាជនខ្មែរមានអារម្មណ៍ភិតភ័យ។ ពិតមែន! សង្គ្រាម និងមនោគមន៍វិជ្ជានយោបាយបានក្រឡុកសតិអារម្មណ៍ប្រជាជន។ នេះនាំឱ្យរបៀបរស់ នៅក្នុងជីវភាពទូទៅនៃសង្គមខ្មែរ ត្រូវបានហ៊ុមព័ទ្ធដោយអំពើហិង្សា។ បើតាមការអប់រំពីបុរាណ ក្មេងៗត្រូវបានហាមឃាត់មិនឱ្យបញ្ចេញមតិ ឬមួយនិយាយស្ដីអ្វីច្រើនទេ។ ទោះបីជាខុសឬត្រូវ ក្មេងនោះត្រូវស្ដាប់មនុស្សចាស់តែម្ដង។ សរុបឱ្យខ្លី ក្មេងៗគ្មានសម្លេងនៅក្នុងគ្រួសារទេ។

លោកហ៊ុន សៀងហាក់ មន្ត្រីសិទ្ធិមនុស្ស នៃអង្គការលីកាដូ បានគូសបញ្ជាក់ឱ្យដឹងថា: "ពេលហូបបាយ បើមានឮក្មេងនិយាយ យើងតែងឃើញចាស់ៗ ស្ដីឱ្យកូនចៅថា ក្មេងនោះឥតមាយាទ មិនគោរពចាស់ទុំ។ ការប្រៀនប្រដៅបែបនេះធ្វើឱ្យក្មេងខ្លបខ្លាច មិនសូវហ៊ាននិយាយច្រើន ឬបញ្ចេញមតិអ្វីទេ។ ទាំងនេះធ្វើឱ្យក្មេងគ្មានឱកាសចូលរួមក្នុងការវិភាគពិចារណាដែលនេះខុសពីទម្លាប់របស់ពួកអឺរ៉ុប"។

## ការជេរស្ដីជាការអប់រំនៅក្នុងគ្រួសារ

ក្រៅពីការគាបសង្កត់បែបបំបាក់ស្មារតី ក្មេងៗក៏បានរងការប៉ះពាល់លើផ្លូវចិត្ត និងអារម្មណ៍ផងដែរ នៅពេលមនុស្សចាស់ស្ដីបន្ទោស។ លោកបណ្ឌិតឡៅ ម៉ុងហៃ ទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមបានចាត់ទុកការអប់រំនេះមានលក្ខណៈហិង្សាហួសហេតុ និងប្រកបដោយសំដីទ្រគោះបោះបោក។ លោកបណ្ឌិតបានពន្យល់ថា: "បើគេខឹងសម្បារកូនចៅ គេតែងជេរថា ធាក់ឱ្យងាប់ឥឡូវ! អាត្រូវគ្រាប់! អាគេកាប់! អាគេបាញ់! នេះវាខ្លាំងហួសហេតុពេក។ យើងឃើញថា ពេលមានកំហឹងឡើងភ្លាម គេដាក់មនុស្សជាស្វ័យប្រវត្តិ ឱ្យស្លាប់តែម្ដង ដោយពុំទាន់ស្រាវជ្រាវ ស្វែងរកខុសត្រូវឡើយ"។ ជាក់ស្ដែង អំពើហិង្សា ជាពិសេសការសម្លាប់ដោយសារហ្វូងមហាជន (សូមមើលអ្នកនាំសារលេខ២៣) ជនសង្ស័យមិនត្រូវបានគេសួររកហេតុផលទេ។ ដូច្នេះហើយប្រជាជនជាអ្នកកាត់សេចក្ដីភ្លាមៗ ដោយផ្ដន្ទាទោសជនរងគ្រោះដល់ជីវិតតែម្ដង។ លោក វង្ស សុធារា សាស្ត្រាចារ្យផ្នែកភាសាវិទ្យាបានវិភាគឱ្យដឹងថា: "ការប្រើប្រាស់ពាក្យសំដីរបៀបនេះ គឺកើតចេញមកអំពីកំហឹងរបស់ឪពុកម្ដាយ។

## កំណាព្យ "ជម្ងឺចងអាឃាត"

កើតជាប្រុសស្រីលើដី
កម្ពុជា ត្រូវស្រលាញ់គ្នា
កុំចិត្តចង្អៀត កុំស្អីបន្តិច
រករឿងវិវាទ តាមចង
អាឃាតឥតពិចារណា។
កុំគុំគួនគ្នាព្រោះតែរឿង
ប្រាក់ កុំតាមកាប់ចាក់
ព្រោះតែរឿងស្រា កុំ
សម្លាប់គ្នាព្រោះតែស្នេហា
កុំបាញ់ប្រហារ ព្រោះតែ
ច្រណែន។ ជាតិយើង
សព្វថ្ងៃបីដូចនាវា ឆ្លង
កាត់គង្គាគ្មានកោះត្រើយ
...។ គង់ ប៊ុនឈឿន

យើងគួរតែដឹងហើយថា ខ្មែរយើងភាគច្រើន គឺឥតបានរៀនសូត្រ ដូច្នេះការអប់រំកូនចៅមិនបានឱ្យដូចគេ អ្នកបានរៀនសូត្រទេ។ ជាទូទៅម្ដាយគឺជាអ្នកអប់រំកូន ពីព្រោះគាត់តែងតែនៅផ្ទះ ហើយគាត់ពុំបានរៀនសូត្រ ដូច្នេះចំពោះការអប់រំកូន គឺគាត់ធ្វើពុំបានជិតដល់នោះទេ"។

## ការនិយមជ្រុលធ្វើឱ្យខ្មែរឆាប់ជឿឈានដល់អំពើហិង្សា

ហួសពីការគិតស្មាន ចរិតរបស់ប្រជាជនខ្មែរ ក៏មានលក្ខណៈពិសេសផងដែរ ដោយសារបានទទួលឥទ្ធិពលពីបរទេសខាងក្រៅ។ បើចម្លងអ្វីមួយពីគេ គឺយើងមិនធ្វើឱ្យដូចគេ មានតែធ្វើហួសហេតុខុសពីធាតុដើម។ លោកជិន សុជាតិ អ្នកស្រាវជ្រាវផ្នែកប្រវត្តិវិទ្យា នៅឯរាជបណ្ឌិត្យសភាកម្ពុជា អះអាងថា: "ពេលធ្វើបុណ្យខួបកំណើត បើយើងធ្វើគឺគគ្រឹកគគ្រេងស្ទើរបាក់មេឃបាក់ដីដូចពិធីមង្គលការអ៊ីចឹង។ យើងមិនបានប្រមាណពីសមត្ថភាពខ្លួនឯងទេ។ ជាក់ស្ដែងករណីបាតុកម្មដុតស្ថានទូតថៃកាលពីខែមករា ឆ្នាំ២០០៣ ។ ការជឿពាក្យចចាមអារ៉ាមឆាប់ធ្វើឱ្យខ្មែរឆេះជុំ និងមានកំហឹងឡើងក្រេវក្រោធដោយប្រើហិង្សាតែម្ដង"។
ស្របនឹងការអះអាងបែបនេះព្រឹត្តិការណ៍ កាលពីឆ្នាំ១៩៩៥ ក៏រឹតតែអាចជួយបញ្ជាក់ឱ្យឃើញច្បាស់ផងដែរថា នៅកាលនោះមានអ្នកកាន់សាសនាគ្រិស្តម្នាក់មកពីឥណ្ឌាបានធ្វើការផ្សព្វផ្សាយថា ខ្លួនអាចជួយព្យាបាលមនុស្សពិការជើង ភ្នែក គ ឬថ្លង់ ឱ្យដើរ មើល និយាយវិញបានដូចដើម។ ដោយឮបែបនោះប្រជាជនខ្មែររាប់ពាន់នៅតាមជនបទចុងកាត់មាត់ញកបានលក់ទ្រព្យសម្បត្តិរបស់ខ្លួនដើម្បីមកចូលរួមកម្មពិធីដ៏ឱឡារិកនាពហុកីឡាដ្ឋានអូឡាំពិកភ្នំពេញ។ ប៉ុន្តែដោយការសន្យារបស់អ្នកផ្សាយសាសនានោះពុំបានដូចអ្វីដែលខ្លួនបានឃោសនា ពេលនោះប្រជាជនខ្មែរដែលពុំបានគិតគូរវែងឆ្ងាយបានដេញវាយប្រហារលើអ្នកផ្សាយសាសនារូបនោះ។ លើសពីនេះពួកអ្នកមានកំហឹងបានបំផ្លាញទ្រព្យសម្បត្តិអស់មួយចំនួន។ ការបង្ហាញឧទាហរណ៍ ទាំងពីរខាងលើអាចឱ្យយើងឃើញថា ខ្មែរឆាប់ជឿគេដោយពុំបានពិនិត្យមើលឱ្យគ្រប់ជ្រុងជ្រោយ។ ជាមួយគ្នានេះដែរកំហឹងច្រឡោតក៏តែងងាយផ្ទុះឡើងណាស់។

## ទិដ្ឋភាពតាមទីសាធារណៈឆ្លុះបញ្ចាំងនូវអំពើហិង្សា

ផ្ទាំងផ្សព្វផ្សាយ និងរូបភាពនានាតាម ទីសាធារណៈបានឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ពីភាពហិង្សា និងជ្រុលនិយមនៅក្នុងសង្គមខ្មែរសព្វថ្ងៃ។ ជាក់ស្ដែង លោកបណ្ឌិតឡៅ ម៉ុងហៃ ក៏បានកត់សម្គាល់លើរូបគំនូរនៅតាមវត្តអារាមមួយចំនួន។ លោកបានលើកជាឧទាហរណ៍អំពីគំនូរទណ្ឌកម្ម ចំពោះអំពើបាបរបស់មនុស្សទូទៅ។ នៅវត្តជីដុះមានរូបគំនូរមួយផ្ទាំងដែលនិយាយអំពីស្ត្រីម្នាក់បំបៅកូន នៅពេលលោកកំពុងតែទេសនាក្នុងវិហារ។ ទណ្ឌកម្មដែលគេដាក់ចំពោះស្ត្រីនោះ គឺឱ្យដង្កូវស៊ីដោះស្ត្រីនោះខ្ទេចខ្ទី ដោយសារទង្វើរបស់ស្ត្រីនោះធ្វើឱ្យប៉ះពាល់ដល់សតិអារម្មណ៍របស់ព្រះសង្ឃ។
"ខ្ញុំគិតថា នេះជាទិដ្ឋភាពពិតប្រាកដមួយ នៅក្នុងជីវភាពរស់នៅរបស់ប្រជាជនយើង។ ខ្ញុំយល់ថា គ្មានហេតុផលអ្វី ដែលត្រូវដាក់ទោសឱ្យស្ត្រីនោះធ្ងន់ធ្ងរបែបនេះទេ។ ផ្ទុយទៅវិញ អ្វីដែលស្ត្រីនោះធ្វើជារបៀបមួយដែលបង្រៀន លោកសង្ឃឱ្យចេះជម្នះ និងផ្ដាច់អារម្មណ៍ កុំភ្លើតភ្លើន"។ ទាំងនេះគឺជាអំណះអំណាងរបស់ លោកបណ្ឌិតឡៅ ម៉ុងហៃ។

## កាលៈទេសៈសង្គ្រាមធ្វើឱ្យគេគិតថាជីវិតគ្មានតម្លៃ

សង្គ្រាមស៊ីវិល ដែលប្រទេសកម្ពុជាបានជួបប្រទះ បណ្ដាលឱ្យប្រជាជនខ្មែរជាច្រើនបាត់បង់ជីវិត។ បុរសភាគច្រើនធ្លាប់បំរើការងារជាទាហាន និងបានឆ្លងកាត់រាល់ការប្រយុទ្ធកាប់សម្លាប់គ្នា។ លោកនី ចរិយា ប្រធានផ្នែកស៊ើបអង្កេតនៃសមាគមអាដហុកបានឱ្យដឹងថា: "តាំងពីរបបលន់ ណុល ជា...

ពិសេសខ្មែរក្រហម ពួកគេមិនឱ្យតម្លៃជីវិតមនុស្សទេ។ ប៉ុល ពតតែងប្រើពាក្យថា ទុកក៏មិនចំណេញដកចេញក៏មិនខាត។ ក្នុងរបបរដ្ឋកម្ពុជា គេយកមនុស្សទាំងហ្វូងទៅធ្វើក-៥។ នៅពេលនោះ គឺមានមនុស្សជាច្រើននាក់ណាស់ ដែលបានស្លាប់ និងធ្លាក់ខ្លួនពិការ។ សរុបឱ្យខ្លីទៅ គេពុំគិតអំពីជីវិតមនុស្សទេ។ សព្វថ្ងៃនេះ មានមនុស្សខ្លះរស់នៅដោយសប្បាយនឹងអំពើព្រៃផ្សៃ ហើយខ្លះទៀតក៏មិនចូលចិត្តទេ"។

តាមរយៈនេះ លោកនី ចរិយា ក៏បានបញ្ជាក់ឱ្យដឹងទៀតថា ជីវិតមនុស្សទោះបីក្រខ្សត់យ៉ាងណាក៏ដោយ ក៏មិនអាចមានអ្វីមួយអាចមកប្រៀបធៀបបានឡើយ។ ដូចករណីតវ៉ា នៅប៉ោយប៉ែតរបស់ប្រជាពលរដ្ឋក្រីក្រ គឺជាការតស៊ូដើម្បីដី ៤ ហិចតា ផ្ទុយទៅវិញកម្លាំងសមត្ថកិច្ចបានបាញ់សម្លាប់ប្រជាជនចំនួន៥នាក់ ដោយឥតស្ដាយស្រណោះ។

តាមរបាយការណ៍នៃសមាគមអាដហុកដែលប្រមូលបាន ឆ្នាំ ២០០៤ បង្ហាញឱ្យឃើញថា អំពើទារុណកម្មទៅលើជនរងគ្រោះ នៅក្នុងអំពើហិង្សាក្នុងគ្រួសារ ដែលកើតមានឡើងនៅក្នុងសង្គមខ្មែរយើងសព្វថ្ងៃនេះ ពីមួយឆ្នាំទៅមួយឆ្នាំ រូបភាពនៃការធ្វើទារុណកម្មកាន់តែសាហាវ និងកាន់តែឃោរឃៅឡើង ដូចជាការជះទឹកអាស៊ីត ការវាយប្រពន្ធ រហូតដល់រលូតកូន បណ្ដាលឱ្យស្លាប់ទាំងម្ដាយទាំងកូន។ ការវាយធ្វើបាប ដោយយកជនរងគ្រោះទៅចងជើងព្យួរ ទៅនឹងមេដំបូលផ្ទះ ហើយវាយធ្វើបាបតាមរូបភាពផ្សេងៗ ដែលពុំធ្លាប់បានឃើញ ឬក៏ពុំដែលបានឮពីមុនមកឡើយ។

ករណីមានអំពើហិង្សាមួយដែលបានកើតឡើងនៅថ្ងៃទី ០៤ កញ្ញា ឆ្នាំ២០០៤ នៅភូមិព្រៃកទាល់ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង គឺនៅក្នុងគ្រួសារមួយនោះ គ្រាន់តែប្រពន្ធមិនឱ្យលុយ៤០០០រៀលឱ្យប្ដីខ្លួន ដើម្បីយកទៅទិញស្រាផឹក ស្រាប់តែពេលនោះបុរសជាប្ដីបានជេរប្រពន្ធ ហើយយករំពាត់មកវាយប្រពន្ធគាត់។ មិនត្រឹមតែប៉ុណ្ណឹង មិនអស់ចិត្ត ប្ដីនោះបានចាប់ប្រពន្ធ ចងដៃនាងទាំងពីរជាប់គ្នា ហើយចងព្យួរទៅលើមេដំបូលផ្ទះ ដោយស្រាតខោ អាវនាងចេញអស់ រួចក៏វាយធ្វើបាបបន្តទៀត និងយកគល់អុសដែលកំពុងឆេះយកទៅដុតលើខ្លួនប្រាណគាត់។

បូលីន ដាវីដ

## សីលធម៌សង្គមខ្មែរធ្លាក់ចុះ

យោងតាមការអង្កេតរបស់សមាគមអាដហុក បានបង្ហាញថា អំពើហិង្សាក្នុងគ្រួសារនៅក្នុងឆ្នាំ២០០៤កន្លងមកនេះ មានចំនួន ៤៣៦ករណី ក្នុងនោះមាន ៦៩% ដែលកើតមានទៅលើគ្រួសារដែលមានការខ្វះខាត និងក្រីក្រ។ អំពើហិង្សាខ្លះក៏ឈានដល់ការកាប់សម្លាប់គ្នាផង ដែរ ដោយគ្រាន់តែមូលហេតុតូចតាចប៉ុណ្ណោះ។

## បែរណា ហ្សីរ៉ូដូ ចាប់អារម្មណ៍លើការធ្វើដំណើរ

"នេះគឺជាលើកទីមួយ ដែលខ្ញុំមានអារម្មណ៍អំពី "រឿងនេះ" នៅក្នុងប្រទេសមួយ"។ លោកបែរណា ហ្សីរ៉ូដូ **(Bernard Giraudeau)** គឺជាតួកុន តួល្ខោន ផលិតករភាពយន្ត និងជាអ្នកនិពន្ធដ៏ល្បីល្បាញនៅប្រទេសបារាំង។ "រឿងនេះ" គឺអំពីអ្វីដែលគាត់ថា មិនដែលធ្លាប់ឃើញនៅក្នុងប្រទេសផ្សេងៗទៀត នោះគឺអំពើហិង្សានៅក្នុងប្រទេសកម្ពុជា គឺអំពើហិង្សាដ៏ស្ងប់ស្ងាត់របស់ប្រទេសមួយ ដែលធ្វើឱ្យគាត់មានមនោសញ្ចេតនាភាន់ភាំង។

គាត់បាននិយាយថា: "មានបញ្ហាច្រើន ដែលខ្ញុំតែងជួបប្រទះនៅតាមផ្លូវធ្វើដំណើរ ដូចជា ការដណ្ដើមផលប្រយោជន៍គ្នា ការលោភលន់ និងការដណ្ដើមអំណាច... មនុស្សជាច្រើនកំពុងបានរស់នៅលើគំនរទុក្ខ និងទុគ៌តភាពរបស់អ្នកដទៃ។ រឿងនេះក៏មានផង ដែរនៅប្រទេសខ្ញុំ (បារាំង)។ ប៉ុន្តែ យើងមានអារម្មណ៍ថា មានបញ្ហាមិនធម្មតាមួយ ដែលកំពុងតែគំរាមកំហែងដល់ប្រទេសកម្ពុជា។ បញ្ហានេះ គេដឹងអំពីវាតាមរយៈការរស់នៅក្នុងភាពបាក់ស្បាត កង្វះខាតនូវក្បួនច្បាប់សំរាប់ជីវិតរស់នៅក្នុងសង្គម ការភ័យខ្លាចអ្នកជិតខាង និងការបះបោរ។

"មុនពេលខ្ញុំទៅកាន់សារមន្ទីរ ខ្ញុំបានទៅកន្លែងចាក់សំរាម។ នេះគឺជាជ្រុងមួយ ដែលធ្វើឱ្យយើងស្គាល់គ្រប់កន្លុកកន្លៀតដែលជាធាតុពិត។ ប៉ុន្តែនៅជ្រុងម្ខាងទៀត យើងមើលឃើញឡាន **Land Cruisers** ជាច្រើនគ្រឿងកំពុងចតនៅលើចិញ្ចើមថ្នល់។ ជ្រុងម្ខាង យើងឃើញសណ្ឋាគាររីកឡើងយ៉ាងផុលផុសនៅខេត្តសៀមរាប ជ្រុងម្ខាងទៀត យើងមើលឃើញសំណល់នៃមហោស្រពទន្លេបាសាក់ ដែលបានឆេះរួចហើយនោះ។ ប៉ុន្តែជ្រុងម្ខាង យើងឃើញ..."។


លោក បែរណា ហ្សីរ៉ូដូ

Photo: DR

"មិនមែនជារឿងធម្មតាទេ ដែលមនុស្សរកស៊ីមានបានយ៉ាងលឿន។ ខ្ញុំមានអារម្មណ៍ខ្មាសអៀនសំរាប់ទីក្រុងសៀមរាប ពេលមកដល់អាងហែលទឹកក្នុងសណ្ឋាគាររបស់ខ្ញុំ វាគឺដូចជារដ្ឋមួយនៅក្នុងរដ្ឋ។ ខ្ញុំមិនធ្វើការវិភាគទេ។ ខ្ញុំមានប្រតិកម្មក្នុងនាមជាអ្នកដំណើរម្នាក់"។

តាមក្បួនចិត្តសាស្ត្រ បើយើងមិនព្យាបាលវិបត្តិផ្លូវចិត្តឱ្យជាដាច់ស្រលះទេនោះ វានឹងលាប់ឡើងវិញ។ នេះត្រូវតែឱ្យជនជាតិខ្មែរដឹងអំពីចំណេះដឹងនេះដោយខ្លួនគេផ្ទាល់។ ប្រសិនបើយុវជន-នារីខ្មែររក្សាទុកក្នុងខ្លួននូវរឿងរ៉ាវដែលមិនអាចពន្យល់បាន វានឹងធ្វើឱ្យលេចឡើងបញ្ហាតាមរបៀបផ្សេងៗ ជួនកាលអាចក្លាយជាអំពើហិង្សាក៏ថាបាន។

សម្រង់ពី កំបូដស័រ





# សុផាលាភ បូជាជីវិតទៅលើគំនូរ

"ប្រសិនបើខ្ញុំមិនបានក្លាយជាអ្នកគូរគំនូរទេ ខ្ញុំនឹងចូលទៅធ្វើជាទាហាន" នេះជាសំដីផុសចេញពីចិត្តរបស់លោកញ៉ើក សុផាលាភ ជាជាងគំនូរមួយរូបសុខចិត្តផ្ចើចិត្តផ្ចើកាយទៅលើផ្ទាំងគំនូរ។


លោកញ៉ើក សុផាលាភលើកបង្ហាញអំពីរូបគំនូរដែលលោកបានគូរ

Photo: M. Kunthear

សម្លេងសម្រឹបជើងស្រាលៗ កំពុងតែបោះជំហានម្ដងមួយៗសំដៅចូលមកក្នុងកូនបន្ទប់មួយ។ នៅក្នុងបន្ទប់តូចនេះ នៅពេលដែលមានអ្នកណាចូលទៅហើយ គឺមិនអាចឥតទ្រាំក្នុងការសរសើរបាន ពីព្រោះមានលំអទៅដោយរូបគំនូរ យ៉ាងល្អប្រណីតរបស់ទឹកដៃវិចិត្រករ និងមានបញ្ឈរដោយរូបអប្សរាមួយនៅលើកំរាលតុធ្វើអំពីហ្វូលប្រកបដោយភាពទាក់ទាញ។ ម្ចាស់បន្ទប់នេះ គឺលោកញ៉ើក សុផាលាភ។

លោកសុផាលាភបានបញ្ចប់ការសិក្សា នៅមហាវិទ្យាល័យសូន្យរូប នាឆ្នាំ១៩៩៤ បន្ទាប់មកលោកបានបន្តសិក្សា នៅមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយវិទ្យា (១៩៩៥-២០០៣)។ លោកមានប្រសាសន៍ឱ្យដឹងថា: "វាជាវាសនារបស់ខ្ញុំ ដែលខ្ញុំបានចូលទៅរៀននៅសាលានោះ ជាលើកដំបូង នៅពេលដែលសាលារើសសិស្ស ឱ្យចូលរៀនដោយធ្វើការប្រឡង ហើយគំនូរដែលជាប្រធានបទសំរាប់រូបខ្ញុំ ក៏ដូចជាសិស្សដទៃទៀត គឺរូបប្រអប់ដីស"។ លោកបញ្ជាក់ទៀតថា វិញ្ញាសានេះមិនមានការលំបាកអ្វីទេសំរាប់រូបលោក។



សព្វថ្ងៃនេះ លោកបានគូររូបភាព ជារូបតុក្កតា (ឬគំនូរឆាករូបភាព) និងរូបគំនូរបុរាណសំរាប់សាលា និងអង្គការផ្សេងៗបានជាច្រើន។ លោកបញ្ជាក់ថា គំនូរតុក្កតាខុសគ្នាពីគំនូរបុរាណ ត្រង់ថា រូបតុក្កតាមិនចាំបាច់គូរលំអិតពេកទេ គឺយើងគូរជាលក្ខណ:ទស្សនវិស័យ (ការស្រមៃ) ឬអាចគូរទៅតាមគំនិតរបស់យើង។ ចំណែកឯគំនូរបុរាណ គឺមិនអាចធ្វើទៅតាមអ្វី ដែលយើងនឹកឃើញបានទេ គឺត្រូវគោរពទៅតាមគោលការណ៍របស់វាជាក់លាក់។ ឧទាហរណ៍ ដូចជារូបព្រះរាម ដែលមានពណ៌ក្រហម គឺយើងមិនអាចគូរដាក់ពណ៌ផ្សេងពីនេះបានទេ។ និយាយរួម គំនូរបុរាណ និងគំនូរតុក្កតា មិនមានគំនូរណាមួយ ដែលពិបាកជាង ឬស្រួលជាងមួយណាទេ គ្រាន់តែថាគំនូរបុរាណ ត្រូវគូរផ្ចិតផ្ចង់ និងឱ្យមើលឃើញច្បាស់ជាងគំនូរតុក្កតា ដែលការគូរមានការខ្ញៀកព្រៀងៗ តែមានការទាក់ទាញដូចគ្នា។ ក្រៅពីការគូរគំនូរ លោកក៏ជាអ្នកគូរប្លង់ផ្ទះ ឬអគារផ្សេងៗផងដែរ។

បុរសវ័យ ៣០ឆ្នាំ រូបនេះ បានបង្ហើបឱ្យដឹងអំពីបំណងរបស់លោកថា លោកមានគំនិតចងក្រងជាសៀវភៅរឿង ទុកជាស្នាដៃ ដោយរូបភាពរបស់រូបលោកផ្ទាល់ ប៉ុន្តែលោកគិតថា លោកពុំទាន់មានសមត្ថភាពគ្រប់គ្រាន់នៅឡើយ។ លោកសុផាលាភបាននិយាយបន្តដោយយកដៃចង្អុលរូបភាពរបស់លោកថា: "ចំណុចពិសេសនៃគំនូរខ្ញុំគឺមានពណ៌ស្អាត ដែលធ្វើឱ្យគេចាប់អារម្មណ៍ភ្លាមនៅពេលគេឃើញ។ នេះជាចំនុចពិសេស ក្រៅពីនេះខ្ញុំមិនដឹងថាមានអ្វី ជាពិសេសទៀតទេ"។

លោកបានបញ្ជាក់បន្ថែមទៀតថា ការផាត់ពណ៌ក៏ជាផ្នែកដ៏សំខាន់មួយរបស់គំនូរផងដែរ ប្រសិនបើយើងគូររូបស្អាតហើយ ប៉ុន្តែយើងបែរជាផាត់ពណ៌មិនបានល្អទេនោះ ក៏មើលទៅហាក់ដូចជាធម្មតាដូច្នេះដែរ។

"នាពេលអនាគត ទោះបីខ្ញុំមានឋានៈបុណ្យសក្តិខ្ពង់ខ្ពស់មានទ្រព្យសម្បត្តិច្រើន ក៏ខ្ញុំនៅតែបន្តគូរគំនូរនេះដដែល ហើយខ្ញុំនឹងយកចំណេះដឹងរបស់ខ្ញុំ ទៅចែកជូនដល់អ្នក ដែលមានចំណង់ចំណូលចិត្តខាងគំនូរនេះដែរ"។ នេះគឺជាការអះអាងដ៏មុឹងម៉ាត់ ផុសចេញពីដួងចិត្តរបស់លោកញ៉ើក សុផាលាភ។

មុំ គន្ធា

## ប្រភេទគំនូរ

គំនូរ ដែលយើងតែងឃើញនៅទីកន្លែងនានា មានបីប្រភេទធំៗគឺ:

គំនូរបុរាណ ដូចជារូបគំនូរលើជញ្ជាំងប្រាសាទបាយ័នជាឧទាហរណ៍។

គំនូរសម័យ មានជាអាទិ៍ដូចជាគំនូរនៅលើផ្ទាំងផ្សាយពាណិជ្ជកម្ម គំនូររឿង គំនូរខ្ញៀក គំនូរតុក្កតា។ល។

គំនូរអរូបិយ ជាប្រភេទគំនូរមួយបែបដែលទាំងអ្នកមើល និងទាំងអ្នកគំនូរមួយចំនួនពិបាកក្នុងការមើល និងយល់។ ចំណែកការគូរវិញនោះ មិនតម្រូវឱ្យមានសំភារ:អ្វីច្រើនពេកនោះទេ ពោលគឺមានតែក្រដាស និងខ្មៅ ដៃគឺល្មមគ្រប់គ្រាន់អាចគូរបានហើយ។

# ពង្រឹងសហប្រតិបត្តិការនៃសាសនាធំៗ

កិច្ចប្រជុំស្តីអំពីការ "ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរសាសនាដើម្បីសន្តិភាព និងភាពសុខដុមរបស់សង្គម" ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាអន្តរសាសនាកម្ពុជាកាលពីថ្ងៃអង្គារ ទី៣១ ឧសភា ឆ្នាំ២០០៥។



កិច្ចប្រជុំធ្វើឡើងក្នុងបរិយាកាសស្និទ្ធស្នាលនិងការយោគយល់គ្នា

Photo: P. Samphy

កិច្ចប្រជុំនេះរៀបចំឡើងនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។ ភ្ញៀវដែលចូលរួមគឺមេដឹកនាំ និងអ្នកតំណាងនៃសាសនាធំៗទាំងបីនៅកម្ពុជា គឺសហគមន៍ពុទ្ធសាសានា ឥស្លាមសាសនា និងគ្រិស្តសាសនា ព្រមទាំងសង្គមស៊ីវិល និងអង្គការផ្សេងៗជាច្រើនទៀតដែលទាំងអស់មានប្រមាណជា៨០នាក់ ដោយស្ថិតនៅក្រោមអធិបតីភាពរបស់ឯកឧត្តម ឈន អៀម រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា។

ថ្លែងក្នុងឱកាសនៃកិច្ចប្រជុំ ព្រះភិក្ខុយស ហ៊ុតខេមចារោ ជាតំណាងមួយរូប នៃពុទ្ធសាសនាមានសង្ឃដីកាថា: "សាសនាមានន័យថាសន្តិភាព។ ចំណែកឯភាពចំរុះគ្នាគឺជាច្បាប់ធម្មជាតិ។ ដូច្នេះ នៅក្នុងជីវិតរស់នៅ យើងត្រូវតែហ៊ានទទួលស្គាល់ និងយល់ព្រមថា មានសាសនាចំរុះ និងត្រូវស្វែងយល់ដោយធ្វើសហប្រតិបត្តិការរវាងគ្នានឹងគ្នាឱ្យបានល្អដើម្បីបានទទួលនូវភាពសុខដុមរមនាទាំងអស់គ្នា"។

ចំណែកលោកយី ធន់ អគ្គលេខានៃក្រុមប្រឹក្សាអន្តរសាសនាមានប្រសាសន៍ឱ្យដឹងដែរថា: "សម័យប្រជុំអន្តរសាសនា នាលើកនេះ គឺត្រូវបានគេធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងរកវិធានការទប់ស្កាត់រាល់បាតុភាព មិនប្រក្រតី ទាំងឡាយដែលអាចនឹងកើតមានឡើងជាយថាហេតុរវាងសាសនា នានា តាមរយៈការអញ្ជើញមេដឹកនាំ និងអ្នកតំណាងគេឱ្យមកធ្វើការពិភាក្សាគ្នា។ ម្យ៉ាងវិញទៀត យើងក៏ចង់ឱ្យសាសនាធំៗទាំងបី ដែលធ្លាប់មានប្រវត្តិយូរលង់នៅកម្ពុជា មានពុទ្ធសាសនា ឥស្លាមសាសនា និងគ្រិស្តសាសនាអាចពង្រឹងកិច្ចសហប្រតិបត្តិការរវាងគ្នានិងគ្នាឱ្យរឹតតែរឹងមាំថែមទៀត"។

បន្ទាប់ពីកិច្ចប្រជុំបានបញ្ចប់ លោកបូជាចារ្យអ៊ុន សុន ជាអ្នកតំណាងឱ្យព្រះសហគមន៍កាតូលិកកម្ពុជា បានកត់សម្គាល់ថាការរៀបចំកិច្ចប្រជុំអន្តរសាសនាឡើងមកនេះគឺល្អប្រសើរ។ មេដឹកនាំសាសនាផ្សេងៗ មានឱកាសទំនាក់ទំនង និងស្គាល់គ្នាកាន់តែច្បាស់។ បន្ទាប់មកពួកគេអាចពន្យល់ដល់សាសនិកធម្មតា កុំឱ្យជឿលើពាក្យចចាមអារ៉ាមផ្តេសផ្តាស ដែលនេះអាចបង្កជម្លោះ និងភាពជាសត្រូវគ្នាទៅវិញទៅមក។

ផាត សំភី

## ធម្មយាត្រាដើម្បីសន្តិភាព

ធម្មយាត្រាលើកទីពាររវាងពុទ្ធសាសនាកម្ពុជា និងជប៉ុនបានប្រារព្ធធ្វើនៅក្រសួងធម្មការ និងសាសនា នាថ្ងៃទី៧ ខែមិថុនានេះ ដែលមានព្រះសង្ឃទាំងពីរមហា-និកាយចូលរួមចំនួនជាង ២០០អង្គ និងព្រះសង្ឃជប៉ុនជាង២០អង្គ។ ពិធីនេះធ្វើឡើងក្នុងគោលបំណងធានាស្ថិរភាពសន្តិភាពក្នុងពិភពលោក ជាពិសេសសន្តិភាពនៅក្នុងប្រទេសកម្ពុជាយើង។

## សុខភាព



Photo: Fr. Omer

លោកស្រី Marissa Regeno-Manampan វេជ្ជបណ្ឌិត ជំងឺកុមារ នៃគ្លីនិកសហគមន៍ និងគ្រួសារពេទ្យ

### អាចខ្ពស់បានមែនឬ?

Green Power ជាឈ្មោះថ្នាំសំរាប់ពន្លូតកម្ពស់។ ការប្រើប្រាស់ថ្នាំនេះសំរាប់អ្នកមានអាយុពី៨ ទៅ២៥ឆ្នាំ ដោយឆ្លងកាត់នូវការត្រួតពិនិត្យឆ្អឹងជាមុន។ សារៈប្រយោជន៍នៃថ្នាំនេះមានបីយ៉ាងគឺ បំប៉នខួរឆ្អឹងខ្នង ខ្សែគ្រោងឆ្អឹង និងគន្លាក់ឆ្អឹង។ វាមិនមែនជាប្រភេទថ្នាំសំរាប់ព្យាបាលជំងឺទេ។ វាជាប្រភេទថ្នាំដែលគេហៅថាថ្នាំបំប៉នសុខភាព (Health Food) សំរាប់ពន្លូតកម្ពស់និងបំប៉នខួរក្បាល។ តាមប្រសាសន៍របស់លោកសុខ លី អ្នកគ្រប់គ្រងផ្នែកលក់បានឱ្យដឹងថា: "ថ្នាំនេះផលិតឡើងពីធម្មជាតិសុទ្ធសាធហើយជាថ្នាំ ដែលមានសារៈសំខាន់សំរាប់អភិវឌ្ឍឆ្អឹង និងភ្នែកឱ្យកាន់តែមានភាពរឹងមាំ និងស្រស់ថ្លា។ ចំណែកឯ លោកវេជ្ជបណ្ឌិតមួយរូប នៃមន្ទីរពេទ្យព្រះសីហនុ(ពេទ្យរុស្ស៊ី) បាននិយាយឱ្យដឹងថា: "ការលូតកម្ពស់ មិនមែនពឹងផ្អែក តែលើការលេបថ្នាំជំនួយ នោះទេ"។ លោកបន្តថា ដើម្បីឱ្យលូតកម្ពស់ គឺអាស្រ័យទៅលើចំណីអាហារដែលយើងហូប។ ជាមួយគ្នានេះដែរ លោកស្រីវេជ្ជបណ្ឌិត Marissa ក៏មានប្រសាសន៍ដែរថា លោកស្រីមិនដែលធ្លាប់បានដឹងថាមានថ្នាំពន្លូតកម្ពស់ទេ។ ដូច្នេះ ការលូតកំពស់ក៏អាស្រ័យទៅលើការបរិភោគចំណីអាហារដែលមានវីតាមីន និងការថែរក្សាសុខភាពឱ្យបានល្អ។

គន្ធា





នៅថ្ងៃនេះ អ្នកបំរើពីររូបបានស្ម័គ្រចិត្តឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ធ្វើជាឧបដ្ឋាកអ្នកបំរើនៅក្នុងចំការព្រះអង្គនៅប្រទេសកម្ពុជា។ លោកទាំងពីរជាសមាជិករបស់ក្រុមសាសនទូតយ៉ារូម៉ាល់ មកពីប្រទេសកូឡុំប៊ី និងអេក្វាឌ័រ។

# ចូលរួមពិធីតែងតាំងឧបដ្ឋាកថ្មី



បងប្រុសយ៉ូហាន អាបេ(រូបឆ្វេង) និងបងប្រុសអ៊ីវ៉ាន់(ដាវ៉ាន់)ជាឧបដ្ឋាកថ្មី

Photo: L. Sovanna

កាលពីថ្ងៃទី៩ មិថុនា ឆ្នាំ២០០៥ នៅព្រះវិហារ សន្តយ៉ូសែបមានមនុស្សម្នាជាច្រើនកុះករ ប្រមាណជា១០០០នាក់ បានអង្គុយនៅតាមកៅអីដែលបានរៀបបំរុងទុកជាស្រេច។ បងប្អូនទាំងនេះមកពីព្រះសហគមន៍ភូមិភាគទាំងបី កំពង់ចាម បាត់ដំបង និងភ្នំពេញ។ ភ្លេងរបាំក្ងោកពោធិ៍សាត់បន្លឺសម្លេងឡើង។ យុវនារីស្លៀកសម្លៀកបំពាក់ពណ៌បៃតងចាស់ដើររាំកាច់ពត់ពេនតាមចង្វាក់ភ្លេង។ ក្បួនដង្ហែ បានធ្វើដំណើរនៅក្រោយរបាំដ៏ល្អ គួរគយគន់នេះ។ យុវជនបួននាក់ស្លៀកពាក់អាវបំពង់វែងពណ៌ស ក្នុងដៃ មានកាន់ឈើឆ្កាង ទៀនមួយគូ និងព្រះគម្ពីរ។ យុវជនទាំងនេះគឺជានិស្សិតទេវវិទ្យាល័យកម្ពុជា។ នៅខាងក្រោយ មានលោកអាចារ្យព្រះសហគមន៍បួនរូប និងលោកឧបដ្ឋាកត្រូវតែងតាំងទាំងពីររូប ព្រមទាំងអស់លោកបូជាចារ្យ និងលោកអភិបាលភូមិភាគទាំងបី។

ពេលអស់លោកសម្រួលឥរិយាបទរួចហើយ កញ្ញាស្រីណេតយុវនារីកំពង់ចាមបានឡើងប្រកាសថា: "នេះជាលើកទី២។ យើងបានជួបគ្នា នៅក្នុងពិធីតែងតាំងឧបដ្ឋាក ដែលកាលពីប៉ុន្មានឆ្នាំមុន ក៏មានពិធីតែងតាំងលោកឧបដ្ឋាកខ្មែរ ចំនួន៥រូបដែរ"។ នាងអានប្រវត្តិបងប្រុសទាំងពីរ ដែលស្ម័គ្រចិត្តទទួលការត្រាស់ហៅពីព្រះជាម្ចាស់ ចូលរៀននៅទេវវិទ្យា-ល័យក្នុងក្រុមសាសនទូតយ៉ារូម៉ាល់ យកជីវិតជាបព្វជិត។

លោកយ៉ូហាន អាបេ អាយុ៣៣ឆ្នាំ និងមកពីប្រទេសកូឡុំប៊ី មានប្រសាសន៍ថា: "ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលបានត្រាស់ហៅខ្ញុំ ឱ្យធ្វើជាបូជាចារ្យ និងធ្វើជាសាសនទូត"។ លោកមានអំណរសប្បាយពិតប្រាកដ ដែលព្រះយេស៊ូត្រាស់ហៅលោកដើម្បីចែកព្រះកាយ និងព្រះលោហិតរបស់ទ្រង់ជាមួយបងប្អូនប្រុសស្រីជាច្រើនរូបទៀត។ ចំណែកឯលោកអ៊ីវ៉ាន់ (ដាវ៉ាន់) អាយុ៣០ឆ្នាំ មកពីប្រទេសអេក្វាឌ័រ បានបញ្ជាក់ពីប្រវត្តិនៃការត្រាស់ហៅរបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់លោកថា: "ខ្ញុំមានអារម្មណ៍ថា ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំដើម្បីបំរើព្រះសហគមន៍ និងធ្វើជាសាសនទូត តាំងពីខ្ញុំនៅជាយុវជន។ ខ្ញុំបានជួយសកម្មភាពសាសនទូតក្នុងព្រះសហ-គមន៍របស់ខ្ញុំ"។ លោកបានឱ្យដឹងថា នៅពេលនោះមានយុវជនជាច្រើនបានចូលរួមសកម្មភាពព្រះសហគមន៍ ដូចជា សួរសុខទុក្ខអ្នកក្រីក្រ អប់រំជំនឿ និងរិះគិតពីជីវិតក្នុងវិញ្ញាណសកម្មភាពសង្គម និងអ្នកជម្ងឺជាដើម។

ចំពោះបទពិសោធន៍រយៈពេល១០ខែនៅកម្ពុជា លោកទាំងពីរ និយាយថា វាគឺជាពេលវេលាល្អមួយដើម្បីស្គាល់វប្បធម៌ខ្មែរ ភាសាខ្មែរ និងបានដឹងច្រើនពីជីវិតប្រចាំថ្ងៃរបស់ប្រជាជន។ លោកទាំងពីរជួយលើកទឹកចិត្តពួកគេ ឱ្យបន្តកសាងព្រះសហគមន៍ដើម្បីភាពរីកចំរើនជាមួយនឹងក្តីសង្ឃឹម។

លោកនឿន គ្រិស្តបរិស័ទពីកំពង់ចាម ដែលបានធ្វើការយ៉ាងជិតស្និទ្ធនឹងលោកដាវ៉ាន់បានប្រាប់ថា: "លោកដាវ៉ាន់ សកម្មណាស់។ លោកធ្វើការយ៉ាងស្និទ្ធជាមួយយុវជនក្មេងៗ និងអ្នកក្រីក្រ"។ ពិសេស លោកជួយលើកទឹកចិត្តយុវជនឱ្យខិតខំរៀនដើម្បីជួយស្តារព្រះសហគមន៍ និងប្រទេសជាតិខ្លួន។

លោកឪពុក អូមែរ អ្នកទទួលខុសត្រូវនៅក្នុងក្រុមនេះ បានបង្ហាញនូវអារម្មណ៍ ដោយបញ្ជាក់ថា: "ខ្ញុំរីករាយខ្លាំងណាស់ដែលនិស្សិតទេវវិទ្យាល័យនៃក្រុមយ៉ារូម៉ាល់ ត្រូវបានតែងតាំងជាឧបដ្ឋាកនៅប្រទេសកម្ពុជាបន្ទាប់ពីក្រុមនេះបានចូលមកក្នុងប្រទេសខ្មែរអស់រយៈពេល១១ឆ្នាំមកហើយនោះ"។

លី សុវណ្ណា

## ប្រវត្តិយ៉ារូម៉ាល់

ក្រុមសាសនទូតនេះបង្កើតឡើងនៅថ្ងៃទី៣ កក្កដា ឆ្នាំ១៩២៧ ដោយលោកអភិបាលភូមិភាគ សង់តា រ៉ូសា ដឺ អូសូសក្នុងខេត្តអាតូហ្គីយ៉ា ប្រទេសកូឡុំប៊ីខាងលិច។ លោកអភិបាលរូបនេះឈ្មោះ អ៊ីហ្គេល អង់ហ្គេល ប៊ីឡេស ហើយបានបំពេញបេស-កកម្មរបស់ខ្លួនក្នុងប្រទេសកម្ពុជា តាំងពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៩៤។ សព្វថ្ងៃ ក្រុមនេះមានលោកឪពុកអូមែរ ហ្វ៊ី-វ៉ាល់ដូ លោកឪពុកអែរណាន់ ពីនីឡា លោកឪពុកយ៉ូហាន ដេយេស៊ូ លោកឪពុកប៉េដ្រូ យេស៊ូ និងលោកឧដ្ឋាក២រូប ដែលទើបតែងតាំងថ្មី។

# ១ មិថុនា នៅកំពង់ចាម















Photos: M. Kunthear; R. Bora; H. Soktheary; S. Noun

## ប្រវត្តិទិវាកុមារអន្តរជាតិ

ក្នុងសង្គ្រាមលោកទី២ មានការវាយប្រហារគ្នារវាងកងទ័ពបារាំង និងអាឡឺម៉ង់។ ទ័ពអាឡឺម៉ង់បានព័ទ្ធជុំវិញភូមិ អ៊ូហាឌូស្ទ័កឡាំងភាគនិរតីប្រទេសបារាំង ហើយបានចាប់ក្មេងនិងស្រីៗចំនួន៦៤២នាក់ដាក់ក្នុងព្រះវិហារមួយ ហើយដុតចោល។ ក្មេងៗជាង២០០នាក់បានស្លាប់។ អង្គការសហប្រជាជាតិបានរំឭក និងបង្កើតទិវាកុមារនៅថ្ងៃទី១ មិថុនា ១៩៤៩។



# ព្រះសហគមន៍ខេត្តកំពង់ចាម ចូលរួមលើកកម្ពស់សិទ្ធិកុមារ

នៅព្រះវិហារកំពង់ចាមកាលពីថ្ងៃទី១ និងទី២ មិថុនា មានប្រារព្ធនូវទិវាកុមារអន្តរជាតិខួបលើកទី៥៦ និងជាលើកទី៦សំរាប់ខេត្តកំពង់ចាម ដែលកាលចាប់ផ្ដើមដំបូងគឺក្នុងឆ្នាំ១៩៩៩។

ក្នុងឱកាសនោះ មានការចូលរួម ពីសំណាក់កុមារា កុមារី លោកអភិបាលអង់តូនី លោកបូជាចារ្យហ្សេរ៉ាល់ និងលោកឈួយ មុងស្រេង តំណាងមកពីមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម ព្រមទាំងលោកគ្រូ អ្នកគ្រូជាច្រើនរូបទៀត។ ក្មេងៗចូលរួម មកពីភូមិ ចំនួន១០ ដូចជា កោះរកា ភូមិថ្មី ក្ដុលលើ ថ្មពេជ្រទីមួយ ថ្មពេជ្រទីពីរ ត្រពាំងកណ្ដោល ចម្លាក់ អណ្ដូងច្រោះ រោងចក្រ និងភូមិបឹងកុក ដែលសរុបទាំងអស់មានគ្នាចំនួន២២៤នាក់ អាយុចន្លោះពី៨ដល់១៦ឆ្នាំ។ ក្នុងឱកាសនោះលោក អភិបាលអង់ តូនី បានឡើងថ្លែងស្វាគមន៍ដល់ភ្ញៀវកិត្តិយស និងប្អូនៗដែលបានមកចូលរួម ដែលមានខ្លឹមសារថា: "ខ្ញុំមានអារម្មណ៍សប្បាយពីព្រោះ ឃើញក្មេងៗមកចូលរួមច្រើន នៅក្នុងថ្ងៃនេះ។ ហើយក្មេងៗទាំងអស់នឹងទទួលបានការអប់រំខ្លះៗដែលកម្មវិធីមានបង្ហាញជូន"។ រីឯ លោកតំណាងមកពីមន្ទីរអប់រំខេត្ត ក៏មានប្រសាសន៍ដែរថា: "ខ្ញុំមានចិត្តរំភើប រីករាយយ៉ាងខ្លាំង ដោយបានមកចូលរួមនឹងទិវានេះ។ វាជាសក្ខីភាពមួយដែលបញ្ជាក់ពីការយកចិត្តទុកដាក់របស់មនុស្សចាស់ចំពោះកុមារ"។ ជាចុងបញ្ចប់ លោកបានធ្វើការផ្ដែផ្ដាំនូវដំបូន្មានល្អៗ ដល់កុមារៗ ផងដែរ។

ក្រៅពីការចូលរួមធ្វើការសំណេះសំណាលនាឱកាសនោះ ក៏មានការប្រឡងរបាំ ប្រឡងរាំ និងកម្មវិធីជាច្រើនទៀតសំរាប់ឱ្យក្មេងៗ ចូលរួមលេងកំសាន្ត។ កុមារាធន់ វ៉ាន់ឌី អាយុ១៣ឆ្នាំ មកពីភូមិកោះរកា បានឱ្យដឹងដែរថា: "ខ្ញុំបានមកចូលរួមនៅក្នុងឱកាសនេះ លើកទី៣ហើយ នៅឆ្នាំនេះខ្ញុំមានរបាំមួយដើម្បីចូលរួមធ្វើការប្រកួតគឺរបាំក្រាប"។ លោកសុខ នឿនគ្រូបង្រៀនផ្នែកអប់រំសុខភាពក៏បានឱ្យដឹងអំពីគោលបំណងនៃពិធីនេះថា: "គឺដើម្បីរំឭកអំពីសិទ្ធិកុមារ និងចង់បញ្ជាក់ថា ពួកគេមានសិទ្ធិដូចមនុស្សធំដែរ"។ ចំណែក លោកបូជាចារ្យហ្សេរ៉ាល់បានប្រាប់ដែរថា: "ទិវាកុមារអន្តរ-ជាតិនេះ គេធ្វើឡើងដើម្បីឱ្យមនុស្សពេញវ័យ និងមនុស្សដទៃៗទៀត នៅទូទាំងពិភពលោកយកចិត្តទុកដាក់ចំពោះសភាពការណ៍កុមារជាពិសេសនៅប្រទេសជាច្រើនតែងតែមានបញ្ហាកើតឡើងចំពោះកុមារ ដូចជា ការធ្វើអាជីវ-កម្មផ្លូវភេទ និងការរំលោភលើពលកម្មកុមារជាដើម។ នៅចុងបញ្ចប់កម្មវិធី មានការចែកជូនរង្វាន់ដល់អ្នកឈ្នះ និងរៀបចំម្ហូបអាហារដល់កុមារៗ ប្រកបដោយភាពសប្បាយរីករាយ។

មុំ គន្ធា









# បារីគឺជាអ្នកសម្លាប់ដែលស្របច្បាប់



**បារីមួយដើមដ៏តូច ដែលគេជក់ គឺជាអាវុធមួយដែលមានកម្លាំងបំផ្លិចបំផ្លាញដ៏ធំធេង មនុស្សប្រមាណ ៤,៩លាននាក់ ត្រូវស្លាប់ជារៀងរាល់ឆ្នាំដោយសារវា។ ចំពោះបារីគ្រប់ប្រភេទចាប់តាំងពីផ្ដើមអុជ បញ្ឆេះ វាបានបញ្ចេញសារជាតិគីមីជាង៤០០០ប្រភេទ រសាត់ជាផ្សែងឆ្ពោះទៅក្នុងសួតរបស់អ្នកជក់។ នៅក្នុងប្រទេសអភិវឌ្ឍន៍ ការប្រយុទ្ធប្រឆាំងនឹងការជក់បារីត្រូវបានប្រកាសឡើងជាខ្លាំង។**

ការសិក្សាមួយរបស់ OMS (អង្គការសុខភាពពិភពលោក) បានបង្ហាញថា ជម្ងឺបណ្ដាលមកពីការជក់បារី គឺបានរីកសាយភាយនៅក្នុងចំណោមប្រជាជនក្រីក្រភាគច្រើន។

លុយ ដែលគេចំណាយទៅលើការទិញបារី មិនត្រូវបានប្រើប្រាស់ទៅលើតម្រូវការចាំបាច់នានា មានដូចជា តម្រូវការខាងចំណីអាហារគ្រប់គ្រាន់ ការអប់រំ និងការថែទាំសុខភាពឡើយ។ នៅក្នុងប្រទេសបង់ក្លាដេស លុយទាំងអស់ដែលគេចំណាយសំរាប់បារីមានទំហំជិតដល់ ១០ដង ច្រើនជាងលុយចំណាយសំរាប់វិស័យអប់រំ។ នៅក្នុងកំរិតថ្នាក់ជាតិប្រជាជនប្រមាណ ១០,៩លាននាក់ ដែលទទួលរងការខ្វះអាហារូបត្ថម្ភ អាចនឹងទទួលបានគុណប្រយោជន៍ ពីរបបអាហារសមរម្យឡើងវិញ ប្រសិនបើលុយដែលចំណាយទៅលើបារីនោះត្រូវបានគេប្រើប្រាស់សំរាប់ទិញគ្រឿងបរិភោគ ដែលនឹងនាំមកនូវវីតាមីនសម្បូរបែបសំរាប់សុខភាពមនុស្ស។




នៅប្រទេសវៀតណាម លទ្ធផលជាលើកដំបូងនៃការសិក្សាមួយបានបង្ហាញថា ក្នុងមួយឆ្នាំៗ លុយដែលអ្នកជក់បារីបានចំណាយសំរាប់ការទិញបារីមានបរិមាណ៣,៦ដង ច្រើនជាងលុយដែលពួកគេចំណាយទៅលើការសិក្សារបស់កូនៗខ្លួន។

នៅទ្វីបអឺរ៉ុប ការប្រយុទ្ធប្រឆាំងនឹងការជក់បារីមានសកម្មភាពយ៉ាងពុះកញ្ជ្រោល។ ការផ្សាយពាណិជ្ជកម្មតាមកញ្ចក់ទូរទស្សន៍ ដែលតែងបង្ហាញឱ្យឃើញនូវរូបភាព ស្ដីអំពីអ្នកជក់បារីម្នាក់ដែលជាបុរសសម័យថ្មីមានថាមពលខ្លាំងក្លា និងប្រកបដោយមន្តស្នេហ៍នោះ លែងឃើញមានគេផ្សាយអស់ជាច្រើនឆ្នាំមកហើយ។ នៅប្រទេសបារាំងតួលេខសិក្សាបានបង្ហាញថា ភាពផ្អែមឆ្ងាញ់ទៅនឹងការជក់បារីបានបង្កឱ្យមាន ២៥០០០ករណីថ្មីៗនៃរោគមហារីកសួតក្នុងមួយឆ្នាំៗ។ នេះគឺខុសឆ្ងាយអំពីរូបភាព "មានមន្តស្នេហ៍" របស់អ្នកជក់បារី។

## យុវជនគឺជាគោលដៅងាយស្រួល

សហគ្រាសផលិតបារីនានាបានយល់យ៉ាងច្បាស់ អំពីទិដ្ឋភាពរួមរបស់យុវជន ដែលតែងសម្ដែងឡើងតាមរយៈភាពចង់ដឹង និងការបំពានរបស់ពួកគេ។ សហគ្រាសទាំងនោះក៏តែងព្យាយាមបញ្ចុះបញ្ចូល និងជំរុញពួកគេឱ្យចាប់ផ្ដើមជក់បារី។

តាមពិត ការជក់បារីមានតម្លៃជានិមិត្តរូបមួយ។ គ្រោងនៃសាច់រឿងបានសម្ដែងឡើងដូច្នេះ: "ខ្ញុំជាយុវជន នៅពេលខ្ញុំជក់បារី ខ្ញុំជាជនឧទ្ទាម ខ្ញុំហ៊ានរំលោភច្បាប់ដែលបានកំណត់ ខ្ញុំជ្រមុជខ្លួនខ្ញុំទៅក្នុងស្ថានភាពគ្រោះថ្នាក់ ខ្ញុំធ្វើខ្លួនឱ្យទៅជាជនឯកោ នៅពេលខ្ញុំសេពរបស់ដែលគ្មានប្រយោជន៍នេះ វានឹងធ្វើឱ្យខ្ញុំក្លាយជាភាវៈរស់មួយដែលប្លែកពីគេ។

ការធ្វើខ្លួនឱ្យខុសគេ ជាជំហានធម្មតាសំរាប់មនុស្សពេញវ័យ ប៉ុន្តែ បើធ្វើវាតាមតែទំនើងចិត្តដោយគ្មានការគ្រប់គ្រង មិនមែនជាផ្លូវមួយដ៏ល្អទាល់តែសោះ ទោះបីបារីត្រូវបានគេលក់ដោយសេរីក្ដី។ កុំភ្លេចថា! និយមន័យនៃគ្រឿងញៀនគឺថា គេមិនអាចអត់វាបានឡើយ។ ជក់បារីធ្វើឱ្យអ្នកជក់នឹងក្លាយខ្លួនទៅជាជន ដែលរស់នៅដោយមិនឯករាជ្យ ព្រមទាំងគ្មានសេរីភាពផងដែរ។

## សារធាតុពិសពុលបំផុតដែលមាននៅក្នុងបារីមួយដើម

អាសេនិក ជាជាតិពុលខ្លាំង ឃើញមានក្នុងសាកសពកណ្ដុរ។ Goudron កើតមានឡើងពេលអុជបារី។ វាជាសារធាតុផ្សំនៅក្នុងកៅស៊ូក្រាលថ្នល់។ នៅពេលវាចូលទៅដល់សួត វាអាចបំរែបំរួលកោសិកាសរីរាង្គ រហូតបង្កើតបានជាជំងឺមហារីក។ ជាតិពុលកាបោនម៉ូណូអុកស៊ីត គេអាចឃើញមាននៅក្នុងផ្សែងចេញពីរថយន្ត។ នៅក្នុងរាងកាយ វារាំងស្ទះដល់ដំណើរដឹកជញ្ជូនអុកស៊ីសែននៃគ្រាប់ឈាមក្រហម បង្កើតបានជាជម្ងឺសរសៃឈាមបេះដូង។ នីកូទីន ជាជាតិគីមីញៀនដែលធ្វើឱ្យអ្នកជក់បារីនៅតែចង់ជក់បន្ត។ អាសេតូន គឺជាជាតិគីមីប្រើសំរាប់សំអាត ឬលាបផ្ទះ។ ការបំភាយរបស់វាបញ្ចេញនូវជាតិពិសពុលខ្លាំងណាស់។

P.R









កាបោនម៉ូណូអុកស៊ីត

### ជាតិពុលផ្សេងៗទៀតក្នុងបារី

អាម៉ូនីញ៉ូម: ជាតិគីមីប្រើសំរាប់សំអាតឥដ្ឋក្រាលផ្ទះ។ ប៊ុយតាន: ជាតិគីមីប្រើសំរាប់ដុត។ អ៊ីដ្រូសែនស្យានិក: ជាតិគីមីពុលប្រើសំរាប់ផលិតគ្រាប់បែកនៅក្នុងសង្គ្រាមលោកលើកទី២។ តួលុយអែន: ជាធាតុរំលាយគីមីសំរាប់ឧស្សាហកម្ម។ ដេ ដេ តេ: ជាថ្នាំសម្លាប់សត្វល្អិត។ កាត់ម្ញ៉ូម: ជាតិគីមីប្រើប្រាស់ក្នុងអាគុយរថយន្ត។ មេតាណុល: ជាតិគីមីប្រើប្រាស់សំរាប់កាំជ្រួច។

ពិភពលោកយើង

# សព្វថ្ងៃនេះកុមារមានសិទ្ធិគ្រប់គ្រាន់ហើយ?

**ទោះបីជា ថ្ងៃ១ មិថុនាគឺជាទិវាមួយ ដែលផ្ដល់កិត្តិយស និងរំឭកដល់កុមារក៏ដោយ ប៉ុន្តែនៅក្នុងប្រទេសជាច្រើន កុមារពុំសូវបានចូលរួមនៅក្នុងពិធីបុណ្យនេះទេ។**

តាមរបាយការណ៍របស់អង្គការ Unicef ក្នុងចំណោមក្មេងៗ ១០០នាក់ដែលទើបនឹងកើត មានក្មេង៤០នាក់គ្មានសញ្ជាតិកំណើត។ ក្មេង២៦នាក់ ពុំបានទទួលការចាក់ថ្នាំបង្ការជម្ងឺ។ ក្មេង១៩នាក់គ្មានទឹកស្អាតផឹក។ ក្មេង៣០នាក់មានកង្វះនូវជីវជាតិអាហារមុនពេលអាយុ៥ឆ្នាំ និង១៧នាក់ទៀត មិនដែលបានទៅសាលារៀនសូត្រទាល់តែសោះ។

## កុមារក្រីក្រ និងចិញ្ចឹមមិនបានល្អ

ក្នុងចំណោមក្មេង១១លាននាក់អាយុក្រោម៥ឆ្នាំ ដែលបានស្លាប់ (តួលេខឆ្នាំ២០០០) ភាគច្រើនគឺជាក្មេងៗ ដែលមានកំណើតនៅក្នុងទ្វីបអាហ្វ្រិក និងអាស៊ីខាងត្បូង។ កង្វះចំណីអាហារ លក្ខខ័ណ្ឌអនាម័យមិនល្អ ព្រមទាំងភាពក្រីក្រ គឺជាមូលហេតុចម្បងចំពោះការស្លាប់នេះ។

## មិនបានទៅសាលារៀន

ជារឿយៗ ក្មេងស្រីៗបានទៅរៀនសូត្រតិចជាងក្មេងប្រុស។ ក្នុងចំណោមក្មេង១៣៥លាននាក់អាយុពី៦ដល់១១ឆ្នាំ ដែលមិនបានរៀន ៨០លាននាក់ជាក្មេងស្រី។ នៅក្នុងប្រទេសក្រីក្រ មានក្មេងមួយភាគបីបានឈប់រៀនសូត្រពាក់កណ្ដាលទីដោយមិនទាន់ទាំងចេះអាន និងចេះសរសេរផង។

## ក្មេងៗរស់នៅក្នុងទាសភាព

ក្មេង២៤៦លាននាក់ដែលមានអាយុពី៥ទៅដល់១៧ឆ្នាំ តែងបានធ្វើការនឿយហត់ខ្លាំង និងប្រកបដោយគ្រោះថ្នាក់នៅក្នុងផ្ទះ តាមផ្លូវ រោងជាង រោងចក្រ និងក្នុងចំការ។ ចំណែកក្មេងៗ ១លាននាក់ទៀត ជួនកាលត្រូវបានគ្រួសាររបស់ពួកគេលក់ឱ្យទៅប្រកបរបរផ្លូវភេទ ជារៀងរាល់ឆ្នាំ។

## អត្ថន័យដ៏ធំ និងប្រកបដោយក្ដីសង្ឃឹម

នៅឆ្នាំ១៩៨៩ អង្គមហាសន្និបាតនៃអង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាមួយស្ដីអំពីសិទ្ធិកុមារ កំណត់នូវកាតព្វកិច្ចរបស់រដ្ឋនានាដែលមានចំពោះកុមារ។ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសហត្ថលេខីនានាផងដែរ។

P.R


Photo: L. Sovanna
នៅកម្ពុជា ស្ថានភាពរស់នៅរបស់កុមារក៏នៅមិនទាន់ល្អដែរ

### អង្គការ Unicef

ដោយត្រូវបានគេបង្កើតឡើងនៅក្នុងឆ្នាំ១៩៤៦ និងមានវត្តមាននៅជាង ១៦០ប្រទេស ជុំវិញពិភពលោក អង្គការនេះទទួលបន្ទុកខាងការពារសិទ្ធិកុមារ។ ស្នាក់ការនៅរាជធានីភ្នំពេញសូមទាក់ទងតាមទូរស័ព្ទ: ០២៣ ៤២៦២១៤-៥។

# យូដូ ជាមាគ៌ាមួយដ៏ទន់ភ្លន់

យូដូជាកីឡាវិជ្ជាគុនមានប្រភពពីប្រទេសជប៉ុននៅសតវត្សទី១៩។ សព្វថ្ងៃ យូដូបានរីកចំរើននៅទូទាំងពិភពលោក ក្នុងនោះក៏មានប្រទេសខ្មែរដែរ ដែលកីឡានេះចូលមកដល់ក្នុងអំឡុងទសវត្សទី៥០។





Photo: P. Samphy

រូបឆ្វេង: លោកឡាច វុទ្ធី គ្រូបង្វឹកបច្ចេកទេសយូដូ និងកាយវិការនៃក្បាច់ចាប់ភ្លែរបស់យូដូនៅពេលហ្វឹកហាត់។

នៅក្នុងឆ្នាំ១៨៨២ លោក ជីការ៉ូ កាណូ(ជនជាតិជប៉ុន) បានបង្កើតក្បាច់កីឡាយូដូនេះឡើងដោយបំប្លែងចេញពីក្បាច់គុនមួយប្រភេទ ហៅថា Jujitsu ដែលមានន័យថាសិល្បៈដ៏ទន់ភ្លន់។ ដូច្នេះហើយទើបយូដូមានន័យថា គឺជាមាគ៌ានៃក្បាច់ប្រយុទ្ធដ៏ទន់ភ្លន់ និងស្លូតបូត។

ប៉ុន្តែទោះបីជាដូច្នេះក៏ដោយ ក្បាច់យូដូមានស្នៀតច្រើន ដូចជាស្នៀតដៃ ស្នៀតជើង និងស្នៀតចង្កេះ។ល។ ក្នុងនោះស្នៀតនីមួយៗ មានបង្កប់ទៅដោយភាពទន់ភ្លន់ ភាពរឹងមាំកម្លាំងខ្លាំងក្លា និងភាពរហ័សរហួនដែលធ្វើឱ្យអ្នកហាត់អាចប្រើប្រាស់ក្នុងការការពារខ្លួន និងវាយបកទៅលើដៃគូរបស់ខ្លួនបានយ៉ាងខ្លាំងក្លា។ ម្យ៉ាងវិញទៀត ដោយក្បាច់ប្រយុទ្ធភាគច្រើនរបស់យូដូគឺជាការចាប់បោកគូប្រកួត។ ដូច្នេះយូដូមានស្នៀតការពារការដួលយ៉ាងប្រសើរ។ នេះគឺជាលក្ខណៈពិសេសមួយក្នុងក្បាច់ប្រយុទ្ធយូដូ។

នៅមុនសម័យសង្គ្រាមឆ្នាំ១៩៧០ យូដូខ្មែរមានការរីកចំរើនខ្លាំង និងមានកីឡាករល្បីៗច្រើន។ នៅក្នុងឆ្នាំ១៩៨៣ ក្លឹបយូដូមួយត្រូវបានបង្កើតឡើង។ នោះគឺក្លឹបយូដូអូឡាំពិក។ លុះមកដល់ឆ្នាំ១៩៨៥ គ្រូយូដូចាស់ៗ ដែលនៅរស់រានមានជីវិតក៏បានរួបរួមគ្នាបង្កើតបានជា ខេមរៈសហព័ន្ធយូដូឡើង ដែលមកទល់សព្វថ្ងៃមានក្លឹបយូដូតែពីរទេ គឺក្លឹបយូដូអូឡាំពិក និងសមាគមយូដូក្រសួងមហាផ្ទៃ។ នៅក្នុងនោះមានគ្រូបង្វឹកទាំងអស់៧នាក់ និងសិស្សប្រមាណជា៣៩នាក់។

លោក ឡាច វុទ្ធី ដែលជាអគ្គលេខាធិការរង នៃខេមរៈសហព័ន្ធយូដូ បានមានប្រសាសន៍ថា: "កីឡាយូដូផ្តល់ឱ្យយើងនូវសុខភាពល្អ និងកម្លាំងកាយមាំមួន។ លើសពីនេះវាក៏ជាការរីតចំណងមិត្តភាពម្យ៉ាងដែររវាងប្រជាជាតិនានា ពេលដែលកីឡាករខ្លួនចេញទៅប្រកួតនៅបរទេសម្តងៗ"។

ផាត សំភី

### ស្នាដៃកីឡាករយូដូខ្មែរ

នៅឆ្នាំ២០០២ កីឡាករ-ការិនីយូដូខ្មែរចំនួន ៤រូប បានទទួលមេដាយមាសចំនួន៤ មេដាយប្រាក់ចំនួន៥ និងសំរិទ្ធិមួយ។ នៅក្នុងការប្រកួតបង្ហាញបច្ចេកទេសនៅទីក្រុងហូជីមិញ នៃប្រទេសវៀតណាម។



# ចាប៉ីដងវែង ជិតស្លាប់?

សព្វថ្ងៃយុវជនភាគច្រើនងាកទៅរកវប្បធម៌បរទេសដែលកំពុងហូរចូលយ៉ាងចាស់ដៃ។ ប្រពៃណីខ្មែរតន្ត្រីបុរាណដែលបន្សល់ពីបុព្វបុរសខ្មែរ ពុំសូវមានអ្នកស្គាល់ទេ ដូចជាចំរៀងចាប៉ីដងវែងជាដើម។

"ចាប៉ីនីមួយៗមិនមែនចេះតែធ្វើឱ្យតែបាននោះទេ"។ នេះជាប្រសាសន៍របស់លោក គង់ ណៃ ជាព្រឹទ្ធាចារ្យមួយរូប ដែលមានបទពិសោធន៍ច្រើនឆ្នាំផ្នែកចាប៉ីដងវែង លោកចាប់ផ្តើមចេញច្រៀងតាំងពីអាយុ ១៥ឆ្នាំ មកម្ល៉េះ។ លោកបានមានប្រសាសន៍ឱ្យដឹងថា ចាប៉ីដែលមានសម្លេងពីរោះទាក់ទាញចិត្តអ្នកស្តាប់ ត្រូវធ្វើស្នូកពីឈើរឹង ដងដោយដើមក្រសាំង ធ្វើសន្ទុះពីខ្នុង់ ធ្វើគីង្គក់ពីដើមធ្នង់ ធ្វើខ្នុង់ដោយឆ្អឹងទើបដាក់ខ្សែដេញទៅមានលាន់សម្លេងពីរោះ មានព្រាយកាន់"។

ម្យ៉ាងវិញទៀត បើមានឧបករណ៍ចាប៉ីនេះល្អហើយ តែបើមិនចេះចាប់ចុងជូនឱ្យបានល្អទេនោះ ការច្រៀងក៏មិនពីរោះដែរ។ បទចំរៀងធំៗរបស់ចាប៉ីដងវែង មានទាំងអស់ចំនួន ៥បទ គឺបទផាត់ជាយ បទសំពោង បទផាត់ជាយក្លាយ បទនរគរាជ និងបទសារោមមេ។ សព្វថ្ងៃនេះ ការនិយមស្តាប់ចាប៉ីដងវែងហាក់ដូចជាមានការធ្លាក់ចុះ ដោយសារតែអារ្យធម៌បរទេសមានការហូរចូលមកច្រើនឡើងៗ ធ្វើឱ្យចាប៉ីដងវែងកាន់តែបាត់បង់ប្រជាប្រិយភាពបន្តិចម្តងៗ។

លោកព្រឹទ្ធាចារ្យមានប្រសាសន៍ថា: "ចាប៉ីដងវែងដែលអាចនឹងរីកចំរើនទៅបាននាពេលអនាគត គឺអាស្រ័យទៅលើរាជរដ្ឋាភិបាល ឬមានសមាគមណាមួយជួយគាំទ្រ"។

ចាប៉ីដងវែងនិយមលេងនៅតាមពិធីបុណ្យផ្កា កឋិន ចូលឆ្នាំ ភ្ជុំបិណ្ឌ ចូល-ចេញវស្សា និងបុណ្យជាតិផ្សេងៗ។ តែក្នុងពិធីមង្គលការក៏អាចលេងបានផងដែរដោយមានច្រៀង ដូចជារឿងប្រវត្តិផ្កាស្លាបី ឬច្រៀងកាត់ខាន់ស្លាជាដើម។ គេមិនប្រើចាប៉ីលេងជាមួយនឹងវង់ភ្លេងទេ គឺលេងតែឯកឯងបរិយាយរឿង ឬច្រៀងចោទឆ្លើយឆ្លងសំណួរវោហារ ចង់ដឹងចាញ់ឈ្នះតាមប្រាជ្ញារៀងៗខ្លួន និងល្បិចស្រាយពាក្យសំដី។

មុំ គន្ធា

### ទម្រង់ឧបករណ៍ចាប៉ីដងវែង

មានខ្សែ២ ឬ៤ មានស្នូកស្មើរមូលស្មើរជ្រុង និងដងវែងងរំពើន។ នៅលើដងមានបញ្ចុះឆ្អឹងជាទ្រនុងតូចៗវាយដង្ហែពីក្រោមខ្សែ។ នៅចំកណ្តាលស្នូក និងក្រោមខ្សែទាំងពីរ មានចោះប្រហោង៤ ទំហំប៉ុនៗគ្នា ប៉ុនចុងចង្កឹះ។



លោកអ៊ីគង់ ណៃ ជាអ្នកច្រៀងចាប៉ីដ៏ល្បីល្បាញ ដែលយុវជនសម័យថ្មីមិនសូវជាស្គាល់រូបគាត់ទេ។

Photo: M. Kunthear

មុខរបរ

# រៀបចំអនាគត

ទីផ្សារការងារនៅកម្ពុជាមានភាពតូចចង្អៀតខ្លាំងណាស់ គឺត្រូវការឱ្យនិស្សិតមានសមត្ថភាពជាចម្បងទាំងចំណេះដឹងបច្ចេកទេស និងការទំនាក់ទំនងល្អនៅក្នុងសង្គម។



យុវនិស្សិតកំពុងតែទស្សនាស្នាដៃជំនាញនៃនិស្សិតរៀមច្បង

Photo: L. Sovanna

"រៀបចំអនាគត" គឺជាប្រធានបទដ៏ធំនៅក្នុងការរៀបចំវេទិកាសាធារណៈសំរាប់យុវនិស្សិត និងយុវបញ្ញវ័ន្ត ដែលត្រូវបានរៀបចំឡើងដោយសភាពាណិជ្ជកម្មបារាំង-កម្ពុជា នៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា(ITC) កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៥កន្លងទៅ ដោយមានការចូលរួមពីសំណាក់ក្រុមហ៊ុនជាតិ និងអន្តរជាតិជាច្រើនទៀតផងដែរ។

គោលដៅនៃការរៀបចំវេទិកានេះ លោកប្រាជ្ញ មិនា ជាអ្នកទទួលបន្ទុកដេប៉ាតឺម៉ង់ការងារ ប្រ្វង់កូហ្វន បានបញ្ជាក់ថា: "យើងរៀបចំវេទិកានេះ សំរាប់បើកផ្លូវ ដល់ក្រុមហ៊ុនទាំងអស់ចាប់ដៃគូធ្វើការរួមគ្នា ផ្លាស់ប្តូរនូវបទពិសោធន៍ការងារទៅវិញទៅមក"។ ក្រុមហ៊ុនដែលមកចូលរួមទាំងអស់ អាចជ្រើសរើសបុគ្គលិកក្នុងឱកាសនេះ និងបង្ហាញនូវសកម្មភាពរបស់ខ្លួន។ នេះធ្វើឱ្យនិស្សិតរបស់យើងដែលទើបនឹងបញ្ចប់ការសិក្សាអាចចាប់អារម្មណ៍ស្វែងរកការងារធ្វើ ឬក៏សំរាប់អ្នកមានការងារហើយ ប៉ុន្តែចង់ផ្លាស់ប្តូររកការងារថ្មី។

លោក មិនា បានបន្តថា: "និស្សិតអាចសួរ អាចទំនាក់ទំនងក្រុមហ៊ុនតាមដែលខ្លួនចូលចិត្ត"។ ជាពិសេស លោកគិតថាកម្មវិធីនេះអាចជួយដល់យុវវ័យរបស់យើងទាំងអស់ក្នុងការបើកចិត្តគំនិតសម្លឹងឆ្ពោះចូលក្នុងទីផ្សារការងារជំនាញ ក្នុងថ្ងៃអនាគត ដែលមានដូចជា វិស្វករធារាសាស្ត្រ អគ្គិសនី សំណង់ គណនេយ្យករ អ្នកបកប្រែភាសាបរទេស និងអ្នកបំរើការតាមយន្តហោះ-ល-។ យុវសិស្សស៊ុន សុធា ដែលបានចូលរួមក្នុងវេទិកានោះ ក៏បង្ហាញនូវចំណាប់អារម្មណ៍ខ្លួនថា: "នេះគឺជាឱកាសល្អណាស់សំរាប់ខ្ញុំ"។ មាននិស្សិតបងៗ ដែលបានបង្ហាញនូវស្នាដៃ និងទេពកោសល្យបច្ចេកទេសខ្លួន ដែលបានរៀន។ ទាំងនេះនឹងជួយឱ្យយុវសិស្សយើង អាចបើកគំនិតដើម្បីរៀបចំអនាគតឱ្យបានល្អប្រសើរ។

លី សុវណ្ណា

### ទំនាក់ទំនងការងារ

បើយុវនិស្សិតចង់ស្វែងរកការងារធ្វើ។ សូមសាកល្បងទាក់ទងមកដេប៉ាតឺម៉ង់ការងារប្រ្វង់កូហ្វនី (DEF)នៅសណ្ឋាគារកាំបូឌីយ៉ាណាបន្ទប់ជាន់ក្រោម។ ទូរស័ព្ទ: ០២៣ ២២១៤៥៣។

## តើនេះជាសត្វអ្វី? សូមភ្ជាប់ចំនុចទាំងនេះតាមលេខរៀង ដើម្បីរកចម្លើយ។ បន្ទាប់មកសូមប្រិយមិត្តផាត់ពណ៌ផង។



## យើងចូលចិត្ត!



នាពេលថ្មីៗនេះ អង្គការស៊ីប៉ាបានចេញផ្សាយនូវសៀវភៅពីរក្បាលដែលមាន២ភាគ និយាយពីលំហអវកាសដែលជាចំណេះដឹងកំររកបាន។ ភាគ១ មានចំណងជើងថា កាឡាក់ស៊ី ផ្កាយ និងភព។ រីឯលំហភាគ២គឺ ការផ្សងព្រេងគ្មានព្រំដែន។ សៀវភៅមួយក្បាលៗ មានតម្លៃ ៣៥០០រៀល និងមានលក់នៅតាមគ្រប់បណ្ណាគារ និងតូបសៀវភៅ។

## រូបទាំងពីរខាងក្រោមនេះមានខុសគ្នា៧ចំនុច សូមប្រិយមិត្តជួយរកផង! តើចំនុចទាំងនោះនៅកន្លែងណាខ្លះ? រួចហើយសឹមផាត់ពណ៌។





Photo: D.R

## ជួយផង! ខ្ញុំកំពុងរងការគំរាមកំហែង

### តើខ្ញុំជានរណា?

ខ្ញុំគឺជាសត្វស្វាត្រោស មានទំហំពីក្បាលដល់ដងខ្លួនប្រវែងពី៤៧០មីលីម៉ែត្រទៅដល់៥៨៥ មីលីម៉ែត្រ។ ខ្ញុំមានទម្ងន់ពី៣,៥ដល់៩គីឡូក្រាម។ ជាទូទៅ ក្បាល ខ្នង ផ្នែកមួយនៃកន្ទុយរបស់ខ្ញុំមានពណ៌ខ្មៅជាងផ្នែកចំហៀងនៃដងខ្លួន។ ផ្នែកខាងក្រោមនៃដងខ្លួនខ្ញុំមានពណ៌ភ្លឺ។ នៅចំទទូលក្បាលរបស់ខ្ញុំមានក្រយៅពណ៌ត្នោតចាស់ ឬខ្មៅដែលមានរោមខ្លី បះត្រង់ៗ មើលទៅរាងដូចម្ទូកកាតឹប។ នៅជុំវិញក្បាល ខ្ញុំក៏មានរោមកញ្ចុំពណ៌ត្នោតខ្ចីបះត្រង់ៗ ដែលវានេះដុះព័ទ្ធជុំវិញស្ទើរតែលុបបាត់ត្រចៀក។

តាមពិតសម្បុរស្បែករបស់ខ្ញុំ តែងតែប្រែប្រួលមិនទៀងទាត់ គឺទៅតាមអាយុ និងភេទជានិច្ច។ ខ្ញុំចូលចិត្តរស់នៅតាមព្រៃស្រោង ព្រៃជ្រុះស្លឹកដែលក្នុងមួយក្រុមមានគ្នាខ្ញុំ ពី៤ទៅ៤០ក្បាលឯណោះ។ នៅក្នុងព្រៃ ខ្ញុំមានអាហារបរិភោគយ៉ាងឆ្ងាញ់។ ទាំងនោះមានដូចជាពពួកផ្លែឈើ ផ្កា គ្រាប់ ធញ្ញជាតិ និងពពួកសត្វល្អិត។ ជាអនិច្ចា! ទោះបីជាគ្នាខ្ញុំ ដែលមានរស់នៅស្ទើរគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា និងត្រូវបានគាំពារដោយច្បាប់យ៉ាងណាក្តី ប៉ុន្តែតាមការពិតជីវិតរស់នៅលើពិភពលោក យើងខ្ញុំតែងតែរងការគំរាមកំហែងពីការបរបាញ់ និងការធ្វើអាជីវកម្មពីសំណាក់ជនខិលខូចជាដរាប។

ប្រែពី "សៀវភៅថនិកសត្វប្រទេសកម្ពុជា"

## ប្លាស្ទិកបំពុលធម្មជាតិ

ជាតិប្លាស្ទិកត្រូវបានផលិតឡើងដោយសារធាតុគីមី ចំរាញ់ចេញពីប្រេង ឧស្ម័ន ធម្មជាតិ និងធ្យូងថ្ម។ ភាគច្រើន ជាតិប្លាស្ទិកត្រូវបានផលិតឡើងសំរាប់ធ្វើជាសំភារៈវេចខ្ចប់។ សំភារៈសំរាប់វេចខ្ចប់ គឺប្រើប្រាស់សំរាប់ទុកដាក់ចំណីអាហារ ឱ្យនៅស្រស់ៗ និងការពារផលិតផលកុំឱ្យខូច មានដូចជា ដបប្លាស្ទិក និងថង់ប្លាស្ទិកជាដើម។

ប្រហែលមួយភាគបីនៃសំណល់តាមផ្ទះ ដែលមនុស្សបង្កើតឡើងគឺជាសំភារៈវេចខ្ចប់។ នៅពេលដែលគេទិញសំភារៈ ឬផលិតផលផ្សេងៗពីផ្សារទៅដល់ផ្ទះ គេតែងតែបោះចោលសំភារៈវេចខ្ចប់ទាំងនោះ។ សំភារៈទាំងឡាយសំរាប់វេចខ្ចប់ ដែលមនុស្សប្រើប្រាស់តែម្តងហើយបោះចោលហៅថា "ផលិតផលប្រើហើយបោះចោល"។ សំភារៈវេចខ្ចប់ដែលផលិតឡើងពីជាតិប្លាស្ទិក គឺជាបញ្ហាដ៏ធំមួយប៉ះពាល់ដល់បរិស្ថានពីព្រោះ : វាជាផលិតផល ដែលមិនងាយនឹងរលាយបានហើយត្រូវស្ថិតក្នុងបរិស្ថានយូរអង្វែង តទៅមុខ។ មិនត្រឹមតែប៉ុណ្ណោះ នៅពេលដែលយើងដុតវា ផ្សែងវានឹងបញ្ចេញសារធាតុគីមីម្យ៉ាងទៅក្នុងអាកាស ដែលជាហេតុបណ្តាលឱ្យមានការបំពុលខ្យល់។ នៅប្រទេសកម្ពុជាមានប្រជាជនប្រហែល ១២លាននាក់ ប្រសិនបើគ្រប់ៗគ្នាប្រើថង់ប្លាស្ទិកបួនក្នុងមួយថ្ងៃនោះ វាគឺជាចំនួនដ៏ច្រើនបំផុតដែលទៅថ្ងៃអនាគតនឹងមានថង់ប្លាស្ទិកនៅពាស[illegible]

**Osmose**



ថង់ប្លាស្ទិកអាចបំផ្លាញបរិស្ថានយ៉ាងធ្ងន់ធ្ងរ ហើយនឹងបំពុលដល់សត្វបានបើពួកវាស៊ីដោយ

Photo: M. Kunthear

### តើបរិស្ថានគឺជាអ្វី?

បរិស្ថានមានន័យថា គឺជាអ្វីៗដែលនៅជុំវិញខ្លួនយើង រួមទាំងខ្លួនយើងផង ដែលរាប់ទាំងភាវៈមានជីវិត និងគ្មានជីវិត។ ភាវៈមានជីវិត និងគ្មានជីវិតទាំងអស់ដែលរស់នៅលើផែនដី តែងមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក និងអាចជះឥទ្ធិពលលើគ្នាទៅវិញទៅមកដោយផ្ទាល់ និងដោយប្រយោល។ បរិស្ថានចែកចេញជាបីគឺ បរិស្ថានធម្មជាតិ បរិស្ថានវប្បធម៌ និងបរិស្ថានបង្កើតដោយមនុស្ស។

# ពិធីជប់លៀងស្វែងរកអត្ថន័យជីវិត


Photo: P. Samphy

នាថ្ងៃទី ២២ ឧសភា ឆ្នាំ២០០៥ បងប្អូនយុវកម្មករ-ការិនី និងយុវជន-នារី ប្រមាណជា៨០នាក់ បានមកជួបជុំគ្នានៅមណ្ឌលកូនជាង Caritas ដើម្បីចូលរួមក្នុងពិធីជប់លៀងមួយ និងឆ្លៀតឱកាសដើម្បីរិះគិតរួមគ្នាស្វែងរកអត្ថន័យនៃជីវិតផ្ទាល់ខ្លួនដើម្បីធ្វើការងារឱ្យបានល្អ។

លោក Yann Defond ដែលជាបុគ្គលិកនៃមជ្ឈមណ្ឌលវប្បធម៌កាតូលិកកម្ពុជា និងជាអ្នកជួយណែនាំបង្កើតកម្មវិធីបានរៀបរាប់ថា: "គោលបំណងសំខាន់នៃពិធីជប់លៀងនេះ គឺចង់ឱ្យព្រះសហ-គមន៍ចាប់អារម្មណ៍លើជីវិត និងការលំបាករបស់កម្មករ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ នៅប្រទេសកម្ពុជាហាក់បីដូចជាមានពិភពកម្មករថ្មីមួយ។ ដូច្នេះ ខ្ញុំយល់ថា គ្រិស្តបរិស័ទមិនត្រូវរង់ចាំ ១០ ឬ ២០ឆ្នាំទៀត ទើបស្រលាញ់កម្មករនោះទេ គឺត្រូវស្រលាញ់ពួកគេ "ឥឡូវនេះ"។ សំភី

# កិច្ចប្រជុំគណៈកម្មការអប់រំភូមិភាគ

គណៈកម្មការអប់រំភូមិភាគបានចាប់ផ្ដើមអង្គប្រជុំលើកទី១របស់ខ្លួន ជាមួយបណ្ដាអង្គការព្រះសហគមន៍កាតូលិកនៅក្នុងភូមិភាគភ្នំពេញកាលពីថ្ងៃទី១២ ឧសភា ឆ្នាំ២០០៥ កន្លងទៅ។ នៅក្នុងសុន្ទរកថាស្វាគមន៍លោកឪពុកអូលី វីយេ ដែលជាប្រធានគណៈកម្មការនេះបានមានប្រសាសន៍ថា: "ជាធម្មតា អង្គប្រជុំនេះតែងប្រព្រឹត្តទៅជាប្រចាំ ប៉ុន្តែពុំដែលបានជួបប្រជុំជាមួយនឹងអង្គការកាតូលិកដើម្បីចែកនូវបទពិសោធន៍ និងរិះគិតរួមគ្នានូវអ្វីដែលអង្គការ និងព្រះសហគមន៍បានធ្វើឡើយ"។ នៅក្នុងអង្គប្រជុំបានរិះគិតនូវសំណួរថា: "តើសកម្មភាពយើងខ្ញុំមានលក្ខណៈគ្រិស្តសាសនាដូចម្ដេច?" សកម្មភាពរបស់អង្គការបានបង្ហាញថា: "យើងធ្វើការប្រកាសដំណឹងល្អនៅក្នុងចំណោមគ្រិស្តបរិស័ទ ប៉ុន្តែធ្វើជាសាក្សីនៃតម្លៃថ្លៃថ្នូរ យុត្តិធម៌ និងចិត្តស្មោះស្ម័គ្រនៃគ្រិស្តសាសនាចំពោះបងប្អូនដែលមិនជឿព្រះយេស៊ូ"។ វណ្ណា

# សូមលាកម្ពុជាមួយរយៈ!

ក្រោយពីបានបំពេញបេសកកម្មអស់ពេល១០ឆ្នាំនៅព្រះសហគមន៍ប្រទេសកម្ពុជា លោកបូជា-ចារ្យអូម៉ែរ ហ្ស៊ីរ៉ាល់ដូនឹងឈប់សំរាករយៈពេល ១ឆ្នាំ ដើម្បីសួរសុខទុក្ខឪពុកម្ដាយនិងបងប្អូនរបស់លោកនៅឯស្រុកកំណើតគឺប្រទេសកូឡុំប៊ី។ លោកក៏នឹងធ្វើការរៀនបន្តទៀតផងដែរ។ រយៈពេលនៃការឈប់សំរាករបស់លោកបូជា-ចារ្យអូម៉ែរ នឹងមានលោកបូជាចារ្យអ៊ែណាន់មកទទួលខុសត្រូវដឹកនាំជំនួសដើម្បីជួយកសាងព្រះសហគមន៍ឱ្យកាន់តែមានភាពប្រសើរឡើង។



Photo: L. Sovanna

# ព្រឹត្តិការណ៍នឹងកើត!

**ខែមិថុនា**

- ថ្ងៃ១៨: មានអង្គប្រជុំសិស្សវិទ្យាល័យសន្តហ្វ្រង់ស័រចំនួន២៥០នាក់ នៅព្រះសហគមន៍ចំការទៀងខេត្តតាកែវ ដើម្បីពន្យល់អំពីមុខវិជ្ជាដែលមានបង្រៀននៅសកលវិទ្យាល័យ។
- ថ្ងៃ១៨-២០: អង្គប្រជុំក្រុមអេម៉ាណូអែលនៅព្រះសហគមន៍កំពង់សោម។

**ខែកក្កដា**

- ថ្ងៃ០៣: មានមនុស្សពេញវ័យចំនួន១៤នាក់ដែលនឹងបានទទួលអគ្គសញ្ញាលាបថ្វាសនៅទីក្រុងកំពង់សោម។
- ថ្ងៃ០៨: សិស្សសាលាមត្តេយ្យ ចំការទៀងនឹងធ្វើដំណើរកំសាន្តទៅខេត្តកំពត។
- ថ្ងៃ១៥: មានពិធីចែករង្វាន់ដល់សិស្សពូកែនៅវិទ្យាល័យសន្តហ្វ្រង់ស័រ-ចំការទៀង។
- ថ្ងៃ២៦-២៨: នឹងមានការរៀបចំនូវសន្និបាតរបស់ព្រះសហគមន៍ទូទាំងប្រទេសដែលផ្ដោតលើប្រធានបទ "អគ្គសញ្ញាព្រះកាយ និងព្រះលោហិតព្រះគ្រិស្ត" ប្រារព្ធនៅព្រះវិហារសន្តយ៉ូសែប រាជធានីភ្នំពេញ។

កម្មវិធីវិទ្យុ: យុវវ័យសម័យទំនើប! មានចាក់ផ្សាយនៅប៉ុស្ដិ៍ FM 99.5 MHz វេលាម៉ោង១:៣០ពេលថ្ងៃ និងផ្សាយឡើងវិញនៅម៉ោង៨:៣០យប់ រៀងរាល់ថ្ងៃសៅរ៍។

**សូមប្រិយមិត្តចូលរួមប្រឡងគំនូរ!**
លក្ខខណ្ឌ: បេក្ខជនអាយុ ពី៧ ទៅ១៦ឆ្នាំ។
ប្រធានបទ ទេសភាពស្រុកស្រែ
ឬការងារកសិករ។ គំនូរ សខ្មៅ ឬពណ៌។
សូមផ្ញើមកព្រះសហគមន៍តាមរយៈលោកឪពុកដែលអ្នករស់នៅជិតបំផុត។
ថ្ងៃកំណត់: ៣០ សីហា ២០០៥។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ អូម៉ែរ ហ្ស៊ីរ៉ាល់ដូ